ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៧ លេខ ១៨ ត្រីមាសទី ០១ ឆ្នាំ ២០១៧

# រាជកិច្ច

ផ្សាយចេញពី

## ទីស្តីការគណៈរដ្ឋមន្ត្រី

### សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១៩៨ ស្តីពី ការតែងតាំង លោក **ហាក់ ប៊ុវិសាល** ជា ឧកញ៉ា ១៧០៤

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១៩៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់កញ្ញា **ឆូ អេស្ទ័រ មីហ្យុន** (CHO ESTHER MIHYUN) ជនជាតិកូរ៉េ សញ្ជាតិ អាមេរិក ១៧០៥

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២០០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហ្ស៊ូ ស៊ូឈី** (HSU TZU-CHI) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ១៧០៦

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២០១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លីម គុន ស៊ុង** (LIM KHOON SUNG) ជនជាតិម៉ាឡេស៊ី សញ្ជាតិ ម៉ាឡេស៊ី ១៧០៧

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២០២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឃ្នីបម៉េឆែល យ៉ូសែប ឆាម** (KNEPLMECHER YOSEF CHAIM) ជនជាតិអ៊ីស្រាអែល សញ្ជាតិអ៊ីស្រាអែល ១៧០៨

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២០៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ស៊ាវ ហ៊ុយមីង** (TSAO HUI MIN) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ១៧០៩

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២០៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ជូ ចុងពៀវ** (ZHU ZHONGBIAO) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរ ឈ្មោះជា **ជូ ហ្សាក** (ZHU JACK) ១៧១០

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២០៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហ៊ូ ស៊ីហ្វុង** (HU SHIFENG) ជនជាតិចិន សញ្ជាតិចិន ១៧១១

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២០៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ អស់លោក លោកស្រី និងកងកម្លាំងប្រដាប់អាវុធ ចំនួន ៥៨ រូប ១៧១២

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២០៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម ឧកញ៉ា លោកជំទាវ អស់លោក លោកស្រី កញ្ញា កងកម្លាំងប្រដាប់អាវុធ និងព្រះសង្ឃ ចំនួន ៧០ រូប/អង្គ ១៧១៤

២៤-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២០៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក លោកស្រី ឧបាសក និងព្រះសង្ឃ ចំនួន ៤៦ រូប/អង្គ ១៧១៦

២៤-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២០៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម ឧកញ៉ា លោកជំទាវ អស់លោក លោកស្រី កញ្ញា ឧបាសក និងព្រះសង្ឃ ចំនួន ៦៦ រូប/អង្គ ១៧១៨

២៤-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២១០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ អស់លោក លោកស្រី និងកងកម្លាំងប្រដាប់អាវុធ ចំនួន ៥០ រូប ១៧២០

២៤-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២១១ ស្ដីពី ការលើកលែងទោសឱ្យទណ្ឌិតឈ្មោះ **ខាំ ខឿន** ១៧២២

២៤-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២១២ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈលោកជំទាវ **សោម សួគ៌ា** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១៧២៣

២៤-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២១៣ ស្ដីពី ការតម្លើងឋានៈ តែងតាំង និងផ្ដល់ឋានៈឯកឧត្តម ០៤ រូប ជាអគ្គលេខាធិការរង តែងតាំង និងផ្ដល់ឋានៈឯកឧត្តម **ប្រាក់ គឹមហុង** ជាទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ១៧២៤

## II-ក្រុមប្រឹក្សាធម្មនុញ្ញ

០៣-៣-២០១៧ -សេចក្តីសម្រេចលេខ ១៨៥/០២៥/២០១៧ កបធ.ច ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៧ លើសំណុំរឿងលេខ ៣៨២/០៨០/២០១៧ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៧ ១៧២៥

## III-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

២៤-០២-២០១៧ -អនុក្រឹត្យលេខ ២៨ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១៧៣៩

២៧-០២-២០១៧ -អនុក្រឹត្យលេខ ២៩ អនក្រ.បក ស្តីពី ការទទួលស្គាល់វិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអូស្ត្រាលី ១៧៤១

២៧-០២-២០១៧ -អនុក្រឹត្យលេខ ៣០ អនក្រ.បក ស្តីពី ការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ ១៧៤៥

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៨៩ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១៧៤៧

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៩០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៧៤៨

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៩១ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ១៧៥០

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៩២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៧៥១

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៩៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ១៧៥២

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៩៤ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ១៧៥៣

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៩៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៧៥៤

២០-០២-២០១៧ -អនុក្រឹត្យលេខ ១៩៦ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ១៧៥៥

២០-០២-២០១៧ -អនុក្រឹត្យលេខ ១៩៧ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ១៧៥៧

២០-០២-២០១៧ -អនុក្រឹត្យលេខ ១៩៨ អនក្រ.តត ស្តីពី ការកែសម្រួលសមាសភាពគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ១៧៥៨

២០-០២-២០១៧ -អនុក្រឹត្យលេខ ១៩៩ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ១៧៦១

២០-០២-២០១៧ -អនុក្រឹត្យលេខ ២០០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ១៧៦៣
២០-០២-២០១៧ -អនុក្រឹត្យលេខ ២០១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ១៧៦៥
២១-០២-២០១៧ -អនុក្រឹត្យលេខ ២០២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ១៧៦៦
២១-០២-២០១៧ -អនុក្រឹត្យលេខ ២០៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៧៦៧
២១-០២-២០១៧ -អនុក្រឹត្យលេខ ២០៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៧៦៨
២១-០២-២០១៧ -អនុក្រឹត្យលេខ ២០៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៧៦៩
២១-០២-២០១៧ -អនុក្រឹត្យលេខ ២០៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៧៨១

## ២-សេចក្តីសម្រេច

០៧-០៣-២០១៧ -សេចក្តីសម្រេចលេខ ១៥ សសរ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ១៧៩១
១០-០៣-២០១៧ -សេចក្តីសម្រេចលេខ ១៦ សសរ ស្តីពី ការជ្រើសរើស ពលទាហាន ១៧៩៤

## IV-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៤-០២-២០១៧ -ប្រកាសលេខ ១៦៧ សហវ.ប្រក ស្តីពី ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ ស្តីពី នីតិវិធីអនុវត្តថវិកាកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ១៧៩៥
១៦-០២-២០១៧ -ប្រកាសអន្តរក្រសួងលេខ ១៦៩ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន របស់ក្រសួងអប់រំ យុវជន និងកីឡា នៅនាយកដ្ឋានបឋមសិក្សា ១៧៩៧
១៦-០២-២០១៧ -ប្រកាសអន្តរក្រសួងលេខ ១៧០ សហវ.ហក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១៧៩៩

នស/រកត/០២១៧/១៩៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ត្រាស់បង្គាប់**

**តែងតាំង :**

**លោក ហាក់ បូវិសាល**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧.១៧០២.២០០

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ១៩៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១៩៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **ឆូ អេស្ទ័រ មីហ្យុន** (CHO ESTHER MIHYUN) ជនជាតិកូរ៉េ សញ្ជាតិអាមេរិក កើតថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦៧ នៅរដ្ឋធានីសេអ៊ូល សាធារណរដ្ឋកូរ៉េ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

រកត. ១៧០២.២០១

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ១៩១ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០២១៧/២០០

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ្សូ ស៊ូឈី** (HSU TZU-CHI) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៥៦ នៅទីក្រុងតៃប៉ិ សាធារណរដ្ឋចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៨៧. ១៧០៤ - ២០៤

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧

លេខ: ១៩០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/៥០១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីម ឃុន ស៊ុង** (LIM KHOON SUNG) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៥៨ នៅរដ្ឋកេដា សហព័ន្ធម៉ាឡេស៊ី។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៤៧.១៧០២.៥០៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ១៨៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/២០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **ឃ្នើបម៉ែនែល យូសែប ឆាម** (KNEPLMECHER YOSEF CHAIM) ជនជាតិអ៊ីស្រាអែល សញ្ជាតិអ៊ីស្រាអែល កើតថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៦ នៅទីក្រុងហ្សេរុយសាឡឹម រដ្ឋអ៊ីស្រាអែល។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរព.១៧០៤.២០៤

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ១៩៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី២៧ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/២០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ស៊ាវ ហ៊ុយមីន** (TSAO HUI MIN) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៥៨ នៅទីក្រុងតៃប៉ិ សាធារណរដ្ឋចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣.៧. ១៧០២.២០៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ១៨៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/៤០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជូ ចុងពៀវ** (ZHU ZHONGBIAO) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៨១ នៅខេត្តជឺជាំង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ជូ ហ្សិក** (ZHU JACK)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរក.១៧០៤.២០៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ១៩៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/២០៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឈរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **ហ៊ូ ស៊ីហ្វេង** (HU SHIFENG) ជនជាតិចិន សញ្ញាតិចិន កើតថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៧៣ នៅខេត្តជឺជាំង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧.១៧៤.២០៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ១៨៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០២១៧/៤០៦

# **ព្រះរាជក្រឹត្យ**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា )

## **ប្រោសព្រះរាជទាន**

នូវ

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-វរសេនីយ៍ទោ **ចាំង សុផាត** អត្ត.៧៨០៩៥ ២-វរសេនីយ៍ទោ **ហ៊ុត រដ្ឋា** អត្ត.៦៦២៦២
៣-វរសេនីយ៍ទោ **ចាន់ សំណាង** អត្ត.៤៨៧៥២ ៤-វរសេនីយ៍ទោ **ឈួយ វណ្ណៈ** អត្ត.១០១៤២
៥-វរសេនីយ៍ទោ **ជា សុផារ** អត្ត.២៣៨៦៥ ៦-វរសេនីយ៍ទោ **ឡាច ម៉ូហ្វត** អត្ត.៦៥៣០២
៧-វរសេនីយ៍ទោ **អ៊ុង ខាន់ណារិទ្ធ** អត្ត.៦២៨០៣ ៨-វរសេនីយ៍ទោ **យុន លីនណេវ៉ូ** អត្ត.៦៨៤៣៣
៩-វរសេនីយ៍ត្រី **ណាក វណ្ណៈ** អត្ត.០៥៧០ ១០-វរសេនីយ៍ត្រី **សេង រិនឌី** អត្ត.៥៨២៤២
១១-វរសេនីយ៍ត្រី **ផាន់ ច័ន្ទកោសី** អត្ត.១៩៦៦៩៨ ១២-វរសេនីយ៍ត្រី **ផាង សុវឌ្ឍ** អត្ត.៥៦០១៧
១៣-វរសេនីយ៍ត្រី **ហ៊ឹម សុខា** អត្ត.៧៤៤៤០ ១៤-វរសេនីយ៍ត្រី **យូ សុព័រ** អត្ត.៦៣៣៤១
១៥-វរសេនីយ៍ត្រី **គុំ ផៃខឿន** អត្ត.៥៥៥៩១ ១៦-អនុសេនីយ៍ឯក **ញែម រិទ្ធី** អត្ត.៥៨៦៧៨
១៧-អនុសេនីយ៍ឯក **គឹម សុភាក់** អត្ត.៧២១៥៨ ១៨-អនុសេនីយ៍ទោ **យ៉េម សារី** អត្ត.៦២៥៣២

ខ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-វរសេនីយ៍ត្រី **ភើត ច័ន្ទនិត** អត្ត.៥៦១៦៣ ២-អនុសេនីយ៍ឯក **ជាន សុចេង** អត្ត.៦៣៤២៣
៣-អនុសេនីយ៍ត្រី **ហេង បូលីណា** អត្ត.៧៨០៩៤

គ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-វរសេនីយ៍ទោ **ទួន ស៊ីម** អត្ត.២៣៧០៩ ២-វរសេនីយ៍ត្រី **គង់ សំអាត** អត្ត.៧២០១២
៣-លោក **សុខ រតនា**

ឃ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-ឧត្តមសេនីយ៍ទោ **ពៅ សាលីដេត** អត្ត.៦២៩៥១ ២-វរសេនីយ៍ឯក **ហេង សារិទ្ធ** អត្ត.៥៧៨៦៣

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា:**

១-វរសេនីយ៍ត្រី **ស្រី សុខម៉ុល** អត្ត.៥៤៤៩១ ២-លោក **អ៊ួន សំអឿន**
៣-ឧបាសក **អំ សុខ** ៤-លោក **គង់ ស៊ីថា**

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ច-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា:**

១-វរសេនីយ៍ឯក **អ៊ី ចំរើន** អត្ត.៥៨៥៩១

ឆ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា:**

១-លោក **សៅ ឡៃន**
២-វរសេនីយ៍ទោ **សុខ ឡេះ** អត្ត.០២០៦៩៦
៣-អនុសេនីយ៍ទោ **ឈឹម ខាសនា** អត្ត.២០៤០២២
៤-អនុសេនីយ៍ត្រី **ហ៊ី ម សំណាង** អត្ត.៧៣៦៩៩
៥-លោកស្រី **សាយ ស្រីណុច**
៦-លោកស្រី **សាយ ច័ន្ទកញ្ញា**
៧-លោកស្រី **ឈឿន បុប្ផានី**
៨-លោកស្រី **កេង សុខមុនីរ័ត្ន**
៩-លោក **ហែម ឧត្តម**

ជ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ:**

១-វរសេនីយ៍ត្រី **លាង ហួង** អត្ត.៦១០៦៨
២-អនុសេនីយ៍ឯក **គីម ចន្ថា** អត្ត.៦៦២៦៩
៣-អនុសេនីយ៍ឯក **លី តារាពិសិដ្ឋ** អត្ត.៦៨២៦៦
៤-អនុសេនីយ៍ឯក **សយ ប៉ោឡាត់** អត្ត.១១៤៦២៣
៥-លោកស្រីអនុសេនីយ៍ឯក **ថេង ឆូរីដា** អត្ត.៦២៥០០
៦-អនុសេនីយ៍ត្រី **ខៀវ សុផាត** អត្ត.៦៤៥៩៤
៧-អនុសេនីយ៍ត្រី **កែវ សុខហេង** អត្ត.៧៦០៨៥
៨-អនុសេនីយ៍ត្រី **ផែន សុធា** អត្ត.៦៩១២០
៩-អនុសេនីយ៍ត្រី **ខៀ វ សីហា** អត្ត.៧៦៣១៥
១០-លោកស្រី **លឹម ចន្ថា**
១១-លោក **ហុង ណារ៉េត**

ឈ-គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ:**

១-វរសេនីយ៍ឯក **ឈួ ចាន់ថន** អត្ត.៥៧៩០៦
២-វរសេនីយ៍ឯក **នួន សុផាត** អត្ត.៥៨០៦៧
៣-វរសេនីយ៍ទោ **សួន សារ៉ាវុធ** អត្ត.៧២១២៨
៤-វរសេនីយ៍ទោ **ចេង ឡេង** អត្ត.៦១៧២៤
៥-វរសេនីយ៍ទោ **គុណ ច័ន្ទរដ្ឋា** អត្ត.៥៦១៦៦
៦-វរសេនីយ៍ត្រី **ជុង គៃផេង** អត្ត.៥៥៣៣៤
៧-វរសេនីយ៍ត្រី **គុណ រតនា** អត្ត.៦៦៧៨៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.១៧០៤.២០៧

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ១៨៥ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ២៤ ខែ កុម្ភះ ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០២១៧/២០៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**
ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **ជាតូបការ**

១-ឯកឧត្តម **អ៊ឹង ម៉ុនអៀង**
២-ឧត្តមអគ្គានុរក្ស **ពៅ ឧុទ្ធី** អត្ត.០០២៦

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-ឯកឧត្តម **សាណែត វឌ្ឍនា**
២-ឯកឧត្តម **ឌួន មាស**
៣-ឯកឧត្តម **ស៊ូ នី**
៤-ឧត្តមសេនីយ៍ទោ **គួន ឡុង** អត្ត.០២២១៨
៥-លោកជំទាវ **ឡាក់ មុនីរស្មី**
៦-ឧកញ៉ា **អ៊ឹង ថារី**
៧-ឧបាសក **អុង ធីង**
៨-លោក **គី គឹមអេន**
៩-លោក **សុភាន ណារ៉េត**
១០-លោកជំទាវ **គយ សុខានី**
១១-លោក **អ៊ី គឹមអួន**
១២-លោក **ហុក និព្វុរុត្ថា**
១៣-លោក **ជា សុខហួរ**
១៤-លោក **ជោរ គឹមហេង**
១៥-ឧត្តមសេនីយ៍ត្រី **ឡាយ សុណាន** អត្ត.២០១៤៧៣
១៦-លោក **យ៉េង ពិសិដ្ឋ**
១៧-លោក **សំ ម៉ុនពៅ**
១៨-លោក **ម៉ុន លីជាឌុង**
១៩-លោកស្រី **គង់ លីឡា**
២០-កញ្ញា **ឈួន ម៉ារី**

គ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-សាស្ត្រាចារ្យ **ហេង សុភាព**
២-Mr. KIM HONG MYOUNG
៣-វរសេនីយ៍ឯក **ស្វាយ សុខសាន្ត** អត្ត.០៦៣០៤

ឃ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-ព្រះតេជគុណសង្ឃបាលិតោ **លន់ សំប៊ី**
២-ឧត្តមសេនីយ៍ត្រី **នួន សរពិសិដ្ឋ** អត្ត.០១៧៦១២
៣-ឧត្តមសេនីយ៍ត្រី **អ៊ុំ គី** អត្ត.០២០៣៧
៤-បណ្ឌិត Sr. Luise Ahrens
៥-លោក **ទេព ផល្លា**
៦-លោក **ពេជ្រ ច័ន្ទរ៉ា**

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ:**

១-អ្នកគ្រូ **ទ៉ូច ចាន់ស៊ីយ៉ា** ២-លោក **ឈុន នុន**
៣-លោក **អែល សុឌ្ឋាទី** ៤-លោក **សេង ទ្រី**
៥-លោក **តាំង ម៉ិនហ៊ុយ** ៦-លោក **ហែម រឿន**
៧-លោក **សំ សិទ្ធិស័ក្តិ** ៨-អនុសេនីយ៍ទោ **លឹម សុវណ្ណឬទ្ធី** អត្ត.៦៤២៧៧
៩-អនុសេនីយ៍ត្រី **ឡាយ រិទ្ធិសាក់** អត្ត.៦០៦៥៥ ១០-អនុសេនីយ៍ត្រី **ញ៉ែម រិទ្ធី** អត្ត.៦០៦៥៤
១១-អនុសេនីយ៍ត្រី **សេង រស្មី** អត្ត.៧១៣៤៣ ១២-អនុសេនីយ៍ត្រី **ចី ប្រុសពៅ** អត្ត.៧៣៧០៨
១៣-អនុសេនីយ៍ត្រី **អ៊ឹង សុរិន** អត្ត.៤៦៦៧៧ ១៤-អនុសេនីយ៍ត្រី **នុង ឌីណា** អត្ត.៤៦៦៤៨
១៥-អនុសេនីយ៍ត្រី **ព្រាប សំតា** អត្ត.៤៦៣៣៨ ១៦-ព្រិន្ទបាលឯក **ម៉ិល ឡាំហេង** អត្ត.៧២៧០៥
១៧-លោក **អេន សុវណ្ណា** ១៨-លោកស្រី **ឌុក សារុន**
១៩-លោក**ឡុច ស៊ីដាណា**

ច-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ:**

១-វរសេនីយ៍ត្រី **ទេស រអេនា** អត្ត.៦៦៩៩៦ ២-អនុសេនីយ៍ឯក **ហាក់ សុខនី** អត្ត.៥៦០៥៦
៣-លោក **ហ៊ុន ពិសិដ្ឋ** ៤-លោក **លី គីមថៃ**

ឆ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ:**

១-Mr. PENG ENG LEE ២-វរសេនីយ៍ឯក **រឿន សារ៉ាត់** អត្ត.០៣៦៦៩
៣-វរសេនីយ៍ត្រី **សុខ មុរ៉ា** អត្ត.៥១១៧៨

ជ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា:**

១-លោក**ផេង សុជា** ២-អនុសេនីយ៍ឯក **យឹម ឆិន** អត្ត.៣៨៩៧៧
៣-អនុសេនីយ៍ឯក **ជ្រា ស៊ីថា** អត្ត.៦៩៤៥១ ៤-អនុសេនីយ៍ទោ **ថូ ចាន់ដារ៉ារ័ត្ន** អត្ត.៥២៧០៩

ឈ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **សេនា:**

១-លោក **លី វ៉ាឈីត**

ញ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរត្ន** ថ្នាក់ **សេនា:**

១-ឧត្តមសេនីយ៍ទោ **សេង សាម៉ីឌី** អត្ត.០៣១៣១៣

ដ-គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ:**

១-ឧត្តមសេនីយ៍ទោ **ផាត សុផានិត** អត្ត.៦១៧១៦ ២-អនុសេនីយ៍ឯក **ពុធ សុភីរ៉ាសិទ្ធិ** អត្ត.៥៦៨៤០
៣-ឧត្តមសេនីយ៍ទោ **ខេង សៅធិបុត្ត** អត្ត.១៦១៩៩ ៤-វរសេនីយ៍ឯក **អ៊ុំ ឈានរិទ្ធិ** អត្ត.០៥២៩៨
៥-វរសេនីយ៍ឯក **យឹម នុទ្ធី** អត្ត.៦៦៧៧៨ ៦-វរសេនីយ៍ទោ **អោម មុន្នីវណ្ណា** អត្ត.១៦៤០៦
៧-អនុសេនីយ៍ឯក **ឆេន សំនិត** អត្ត.៥៦៣៦៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៣/០២.២០៩

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ១៥៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/២០៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ ឯកឧត្តមបណ្ឌិត **ខួន ញឹល**
ប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **ជាតូបការ**

១- ឯកឧត្តម **ឡុង ហ៊ីប** ២- ឯកឧត្តម **អ៊ុង រឿងរិទ្ធ**
៣- ឯកឧត្តម **រស់ច័ន កុសល** ៤- ឯកឧត្តម **គឹម សាន់**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១- ឯកឧត្តម **ហ៊ី ច័ន់ថន** ២- ឯកឧត្តម **ខួន រាសី**
៣-ឯកឧត្តម **អ៊ុំ សឿង** ៤- ឯកឧត្តម **លុក សម្បត្តិ**
៥- ឯកឧត្តម **ឈួ ទិចិត្រ** ៦- លោក **អ៊ុត ដារ៉ា**

គ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១- ឯកឧត្តម **ប៊ុន ធី** ២- ឯកឧត្តម **ឡៅ លីហុក**
៣- ឯកឧត្តម **ឃិន សុខ**

ឃ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា:**

១- លោកស្រី **លឹម ផល្លា** ២- លោកសាស្ត្រាចារ្យមហាបរិញ្ញាវេជ្ជបណ្ឌិត **សុខ ជូរ**
៣- លោក **ទូច សុខា**

ង-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា:**

១- លោក **ជាម ប៊ុនធឿន**

ច-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា:**

១- ព្រះតេជគុណអគ្គមុនី **ឡាច សារិទ្ធ** ២- ព្រះតេជគុណសង្ឃនាទោ **សៀក សេង**
៣- លោក **អេង ឌួច** ៤- លោក **សុខ ហួន**

ឆ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ:**

១- ឯកឧត្តម **ហាង សុផុន** ២- ព្រះតេជគុណអគ្គាភិរក្ខិតោ **មាស សុភារ៉ា**
៣- លោក **សន រដ្ឋា** ៤- លោក **កែ កញ្ញនា**
៥- លោក **អ៊ឹម ម៉ុន** ៦- លោក **គៀន គឿន**

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ជ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:

១- ព្រះតេជគុណសាសនពុទ្ធិកោ មុត សុខា
២- លោក អួង សារឿន
៣- លោក សៀ ឡុងឆារ៉ា
៤- លោក ញ៉ែម ពីង
៥- លោក ម៉ែន ភ្លូ
៦- លោក ហោ គឹមឈាន
៧- លោក ខ្មៅ ម៉ិនហ៊ីម

ឈ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា:

១- ព្រះតេជគុណមហិន្ទត្ថេរ អេង ហ៊ាង
២- ព្រះតេជគុណរតនាត្ថាណោ គង់ ស្រៀង
៣- លោក សុគ៌ ច័ន្ទតារា
៤- លោក ម៉ៅ ម៉ិនធូរ
៥- លោក ផេង តារម្យ

ញ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ:

១- ឧបាសក ម៉ែន សឿន
២- ឧបាសក ញ៉ូង ម៉ុត
៣- ឧបាសក ថោង ហៀង
៤- ឧបាសក ធីវ សៀង
៥- ឧបាសក ជូ ខុន
៦- លោកស្រី អ៊ុច ចន្ថា
៧- លោក ឈឹម ស្រេង

នស.រកម.១៧០២.២១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៧

លេខ: ២០៩ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

នស/រកត/០២១៧/២០៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន**
ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **ជាតូបការ**

១-ឯកឧត្តម **ថាន់ តិរុណា**
២-ឯកឧត្តម **លីវ សុភក្ត្រា**
៣-លោកជំទាវ **ខ្លូត ធនផ្កា**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-ព្រះគ្រូព្រះព្រហ្មគិរីធម្មបាល **នូ ខិន**
២-ព្រះសមណឧត្តម **ពេញ សុចន្ទី**
៣-ព្រះគ្រូសិរីវង្សា **បាន ទូច**
៤-ព្រះបញ្ញាសីលោ **ខែម ណោម**
៥-ព្រះអគ្គញាណ **ស្រេង សុខា**
៦-ព្រះភិក្ខុ **ញ៉ែម សារម្យ**
៧-ឯកឧត្តម **ថាង គិតមែន**
៨-ឯកឧត្តម **ឈិន ម៉េង**
៩-វរសេនីយ៍ត្រី **ហាន់ តារា** អត្ត.០២៥៣១៥
១០-អនុសេនីយ៍ឯក **ព្រហ្ម ឫទ្ធី** អត្ត.១៦៦២៤
១១-ឧបាសក **គោម អឿន**
១២-វេជ្ជបណ្ឌិត **យូ ស៊ីណា**
១៣-វេជ្ជបណ្ឌិត **ហ៊ីង កល្យាណា**
១៤-វេជ្ជបណ្ឌិត **ឆាប់ គុណា**
១៥-វេជ្ជបណ្ឌិត **ម៉ោញ ថន**
១៦-វេជ្ជបណ្ឌិត **ខាល ច័ន្ទដារិទ្ធ**
១៧-លោកស្រីវេជ្ជបណ្ឌិត **ឡៅ រតនា**
១៨-ទន្តបណ្ឌិត **អ៊ិន ពៅ**
១៩-គ្រូពេទ្យ **សឹម សឿន**
២០-លោកស្រី **ប៊ុទ្ធា ផានី**
២១-លោក **ឡុង សយសុធី**
២២-លោក **យួន សុជាតិ**

គ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរត្ន**
ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-ព្រះគ្រូសិរីវុឌ្ឍី **ច័ន្ទ តិន**
២-ព្រះគ្រូបញ្ញាវិមនោ **សរ រស្មី**
៣-ឯកឧត្តម **គីម រស្មី**
៤-ឯកឧត្តម **ស៊ុនី ចន្ទ្រាសិដ្ឋ**
៥-អនុសេនីយ៍ត្រី **សែ ឫទ្ធី** អត្ត.១៣៤១៧៧
៦-កញ្ញា **ហុក និច្ចកេសា**

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ឃ-គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-Prof. Dr. Prayoon Mererk Dhammachitto ២-Mr. TOZAWA MASAO

៣-Mr. THOMAS JACOBS

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា:**

១-ព្រះតេជគុណ **ឯក វឿត** ២-ព្រះញាណវង្ស **សៅរ៍ មុនី**

៣-ឯកឧត្តម **ផាន់ ម៉ិនធឿន** ៤-លោក **គីម សុវណ្ណឌី**

៥-លោក **សេក សុខុម** ៦-លោក **កុយ សុខុម**

៧-លោក **ឌិត ខេមរា** ៨-លោក **ស៊ិន ប៊ុល**

៩-វរសេនីយ៍ត្រី **សុខ ឧត្តម** អត្ត.១៩៥៤៩៥ ១០-អនុសេនីយ៍ឯក **ស៊ិន សុវណ្ណា** អត្ត.៤១១០៨

១១-លោក **លួន មង្គល** ១២-លោក **ស៊ូនី សិទ្ធិសោម**

ច-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា:**

១-ព្រះតេជគុណ **ផាត់ សុខេម** ២-ឧកញ៉ា **ហេង លី**

៣-លោកជំទាវ **គី សុផ្លាឃុន ឌុច** ៤-លោក **សុខ ផល្លា**

ឆ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរត្ន**

ថ្នាក់ **មហាសេនា:**

១-អ្នកអង្គបណ្ឌិត **ស៊ីសុវត្ថិ ឬទ្ធីរ៉ាវង្ស** ២-ឧបាសក **ខេង សារុន**

ជ-គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា:**

១-Ven. Pheer Phongsuphap Sujato ២-Ven. Dr. Show Pholcharoen Dhassaniyo

ឈ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរត្ន**

ថ្នាក់ **ធិបធិន្ទ:**

១-ព្រះគ្រូសង្ឃប្បជ្ជោតោ **សំ ម៉ាន់ថា** ២-លោកស្រី **ចក់ សុខចាន់**

ញ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សរិទ្ធ:**

១-ព្រះភិក្ខុអគ្គប្បញ្ញោ **ប៉ោត សុភិន** ២-សាស្ត្រាចារ្យ **ច័ន្ទស្វាង ឌុឌ្ឍិ(ឌុន)**

៣-លោកស្រី **ណែម សុណាត** ៤-លោក **ជ័យ សាផុន**

៥-លោក **អួន ឌុត្ថា** ៦-អនុសេនីយ៍ទោ **ឃឹម ឌីណារ៉ូ** អត្ត.៧៦០៩៦

៧-អនុសេនីយ៍ត្រី **អេង ចំរើន** អត្ត.៧៥៧៥០ ៨-អនុសេនីយ៍ត្រី **ត៉ុត្រា តិវ៉ាល់** អត្ត.៧៦១០៩

៩-លោកគ្រូ **គ្រួច ឡៀន** ១០-លោក **ហុក គីមហាន**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣ស.១៧០២.២១១

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ២០៧ ស.ណ

**សំណៅចម្លងមានអធិប្បាយការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

នស/រកត/០២១៧/២១០

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-អនុសេនីយ៍ឯក **វ៉េន រ៉ាត់** អត្ត.៥៤១៣៤
២-អនុសេនីយ៍ឯក **សទ្ធាភ សទ្ធាវឌ្ឍ** អត្ត.៧៣២៥១
៣-អនុសេនីយ៍ទោ **ជា សំណាង** អត្ត.៣៧៩៤១
៤-អនុសេនីយ៍ទោ **ឈន់ វុទ្ធី** អត្ត.៥៥៣០៣
៥-អនុសេនីយ៍ត្រី **អ៊ុក វុត្ថា** អត្ត.៧៣១៤២
៦-អនុសេនីយ៍ត្រី **អ៊ិន សុភាព** អត្ត.៧៨១៦៦
៧-អនុសេនីយ៍ទោ **សាក់ សុផ្លារ៉ូ** អត្ត.៦៤០២៣
៨-អនុសេនីយ៍ត្រី **វ៉េន សុភ័ក្រ** អត្ត.៧៤១៧៧
៩-លោកសាស្ត្រាចារ្យ **យឹម បញ្ញា**
១០-លោកស្រី **ម៉ឿន សុធីតា**
១១-លោកស្រី **អ៊ុំ សៅលី**
១២-លោក **គង់ សុភាព**
១៣-លោក **ខៀវ ចក្រាវុធ**
១៤-លោក **ឯម យ៉ារ៉ា**
១៥-លោក **ផាន់ ឡូន**
១៦-លោក **ប៉ោះ បូណា**
១៧-លោក **ខិន ហ៊ីន**
១៨-លោក **ថា សុភ័ក្រ្ត**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា:**

១-ព្រះគ្រូ **តូច ពៅជ្រ**
២-លោក **បាន សុវណ្ណតារា**
៣-លោក **លី វឌ្ឍនា**

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ:**

១-លោក **សេង ដារ៉ា**
២-លោក **ឡុត គុយហេង**
៣-លោក **នូ ធនប៊ុណ្ណា**
៤-លោក **អេន សុវណ្ណ**
៥-វរសេនីយ៍ឯក **សៀង ប៊ុណ្ណារ័ត្ន** អត្ត.៦៦៩៧៩
៦-វរសេនីយ៍ឯក **ឈួន សុវណ្ណគិរី** អត្ត.៦៤១៨៧
៧-វរសេនីយ៍ទោ **ហ៊ី សុភ័ក្រ្ត** អត្ត.៥៧៤៥៤
៨-វរសេនីយ៍ទោ **អ៊ុក វិមល** អត្ត.៦២៧៤៣
៩-លោកស្រីវរសេនីយ៍ត្រី **គឿក ម៉ាឡា** អត្ត.៦៦៥៤៥
១០-វរសេនីយ៍ត្រី **ឌី រដ្ឋាណារ៉េត** អត្ត.៦៦៨០៧
១១-លោក **ជា រិនវិសាល**

ឃ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ:**

១-អនុសេនីយ៍ទោ **ផល សុគន្ធា** អត្ត.៦៣៦៨៨
២-អនុសេនីយ៍ទោ **សែ ហួត** អត្ត.៧០៧១៦
៣-អនុសេនីយ៍ត្រី **ឃុន វាសនា** អត្ត.៧៦១០២
៤-អនុសេនីយ៍ត្រី **គោត ចាន់រតនៈ** អត្ត.៧៤៧០៤
៥-[illegible]អនុសេនីយ៍ត្រី **មាស ច័ន្ទភក្តី** អត្ត.៧៧៥១២
៦-លោក **អ៊ិង ណាង**
៧-[illegible]តាអាចារ្យ **ស៊ឹង សុតារា**
៨-លោក **ហេង យីស្រ៊ិន**
៩-លោក **ឃុត ពេង**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ:**

១-លោក **សល មនោ** ២-លោក **សាំខ ចាន់ថៃ**

ច-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា:**

១-លោកតាអាចារ្យ **ខ៉ែត សំបូរ** ២-លោកយាយ **គួច សុខអេង**

៣-លោក **លឹម ហ៊ុយ** ៤-លោក **តាគ ស៊ីវ**

៥-លោក **ខ៉ែត ណុប**

ឆ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ:**

១-វរសេនីយ៍ទោ **សួន ស៊ីន** អត្ត.០៦១៩៤ ២-វរសេនីយ៍ត្រី **សុខ សំណាង** អត្ត.៧១៩៤៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

ចារលេ. ១៧០២.២១៧ **នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ២០៨ ស.ណ

**សំណៅចម្លងចេញពីច្បាប់ដើម ដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/២១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានលើកលែងទោសឱ្យទណ្ឌិតឈ្មោះ **ខាំ ឌឿន** ភេទប្រុស អាយុ ៥២ឆ្នាំ ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ ពីបទៈ ទទួលសំណូក បំផ្លាញបរិស្ថាន និងផ្តល់ព័ត៌មាននូវរបាយការណ៍ក្លែងបន្លំជាលាយល័ក្ខអក្សរ តាមអំណាចសាលក្រមស្តាពរលេខ ១៣៨ "ខ" ចុះថ្ងៃទី ២៣-១១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ៕

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរសរ.១៧/០២.២១៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ២១៨ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/២១២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ទ្រង់ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈលោកជំទាវ **សោម សុគន្ធា** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារណៈ ១៧០២.២១៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ២១៦ ស.ណ
**សំណៅចម្លងដែលមានអត្ថន័យដូចច្បាប់ដើម សម្រាប់ការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/២១៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែ កក្កដា ឆ្នាំ ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤ ស្តីពីការកែតម្រូវមាត្រា១ និងមាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៥/១១៤១ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រី ដែលមាន ឋានៈស្មើ
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តម្លើងឋានៈអគ្គលេខាធិការរង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ០២រូប៖

១-ឯកឧត្តម **ញឹក ប៊ុនរិទ្ធ** មានឋានៈស្មើ រដ្ឋលេខាធិការ
២-ឯកឧត្តម **ម៉ា នរិទ្ធ** មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២** : តែងតាំង និងផ្តល់ឋានៈមន្ត្រីរាជការ ២រូប ជាអគ្គលេខាធិការរង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ៖

១-ឯកឧត្តម **យិន យុនជ័យ** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២-ឯកឧត្តម **ជា ប្រុណិត** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ៣** : តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ទ្រាក់ គីមហុង** ជាទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ៤** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ខល.១៧០២.២១៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ២១៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ៣៤២/០៨០/២០១៧
ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧

**សេចក្តីសម្រេច**
លេខ : ១៨៥/០២៥/២០១៧ កបធ.ច
ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានឃើញលិខិតលេខ ០៧៥ រ.ស ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែ ក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ១០:០០ ព្រឹក។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របតាមមាត្រា១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ មាន **ពីរមាត្រា** និងមានខ្លឹមសារដូចខាងក្រោម÷

**មាត្រាមួយ.-** ច្បាប់ស្តីពីគណបក្សនយោបាយដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ÷

-ចំណងជើងជំពូកទី៤ ត្រូវបានកែប្រែទៅជាជំពូកទី៤ថ្មី អង្គការនានា និងថ្នាក់ដឹកនាំរបស់គណបក្សនយោបាយ។

-ចំណងជើងជំពូកទី៩ ត្រូវបានកែប្រែទៅជាជំពូកទី៩ថ្មី វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ។ មាត្រា៦ មាត្រា១២ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២៥ មាត្រា២៦ មាត្រា២៩ មាត្រា៣៤ និងមាត្រាទាំងឡាយពីជំពូកទី៩ ដល់ជំពូកទី១១។

**មាត្រាពីរ.-**ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយខាងលើនេះ បានធ្វើវិសោធនកម្មទៅលើ ២២ មាត្រា ដូចខាងក្រោម÷

• មាត្រា៦.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៦.-ថ្មី ដោយមានបន្ថែម ២ ចំណុច÷

*“ - ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ*

*- ធ្វើការញុះញង់ដែលអាចនាំឱ្យមានការបែកបាក់ជាតិ ”*

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា៤១ និងមាត្រា៥២ នៃរដ្ឋធម្មនុញ្ញ

• មាត្រា១២.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា១២.-ថ្មី ដែលចែងពី *“មានតែប្រជាពលរដ្ឋខ្មែរដែលមានអាយុយ៉ាងតិច១៨ (ដប់ប្រាំបី)ឆ្នាំ និងមានសិទ្ធិពលរដ្ឋប៉ុណ្ណោះ ដែលអាចចូលជាសមាជិកគណបក្សនយោបាយបាន។”*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា៣៤ ថ្មី និងមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា១៧.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា១៧.-ថ្មី ដោយមានបន្ថែមថ្មី ២ វាក្យខណ្ឌ គឺ វាក្យខណ្ឌទី៣ និងទី៤ ដែលចែងពី *"គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំឱ្យមានប្រធាន និង អាចមានអនុប្រធានតាមការចាំបាច់។ ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ ត្រូវជ្រើសរើស ដោយអនុវត្តតាមលក្ខន្តិកៈនៃគណបក្សនយោបាយនីមួយៗ។*

  *អាណត្តិ ភារកិច្ច ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការដឹកនាំរបស់គណបក្ស នយោបាយនីមួយៗ ដូចមានចែងខាងលើនេះ ព្រមទាំងអង្គការដឹកនាំផ្សេងទៀតរបស់គណបក្ស នយោបាយត្រូវកំណត់ក្នុងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយ។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា១៨.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា១៨.-ថ្មី ជាមាត្រាតាក់តែងថ្មីដែលចែងពី *"ពលរដ្ឋទាំងពីរភេទ ដែលមានសញ្ជាតិខ្មែរពីកំណើត និងមានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ អាចធ្វើជាប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬធ្វើជាសមាសភាពនៃអង្គការដឹកនាំនៃ គណបក្សនយោបាយបាន។*

  *ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការ អចិន្ត្រៃយ៍នៃគណបក្សនយោបាយ មិនត្រូវជាបុគ្គលដែលជាទណ្ឌិតជាប់ទោសដាក់ពន្ធនាគារ ពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរទោសឡើយ។*

  *ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការ អចិន្ត្រៃយ៍នៃគណបក្សនយោបាយ ត្រូវបាត់បង់នូវតួនាទីរបស់ខ្លួន ក្នុងករណីណាមួយដូចខាង ក្រោម ÷*

  *- សាមីខ្លួនទទួលមរណភាព។*

  *- សាមីខ្លួនបានសុំលាឈប់ជាលាយលក្ខណ៍អក្សរ។*

  *- សាមីខ្លួនត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរ ទោសលើកលែងតែទោសនោះត្រូវបានលើកលែងទោសដោយព្រះមហាក្សត្រ។*

  *គណបក្សនយោបាយ ត្រូវចាត់នីតិវិធីដើម្បីជំនួសប្រធានគណបក្សនយោបាយដែល បាត់បង់តួនាទី ដូចមានចែងក្នុងកថាខណ្ឌខាងលើ ក្នុងរយៈពេលយ៉ាងយូរ ៩០ (កៅសិប)ថ្ងៃ គិតពី ថ្ងៃបាត់បង់តួនាទីនោះ។*

  *បទប្បញ្ញត្តិនេះ ក៏ត្រូវយកទៅអនុវត្តផងដែរចំពោះបុគ្គលដែលមានតួនាទី ឬសិទ្ធិអំណាច ប្រហាក់ប្រហែលទៅនឹងប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬសមាសភាពនៃគណៈកម្មា-*

*ធិការនាយក ឬ គណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ។ "*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា១៩.-ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា១៩.-ថ្មី ជាមាត្រាតាក់តែងថ្មី ដែលចែងពី *"ក្នុងរយៈពេលយ៉ាងយូរ ១៨០ (មួយរយប៉ែតសិប)ថ្ងៃ បន្ទាប់ពីគណបក្សនយោបាយ ត្រូវបានបង្កើតឡើងស្របតាមមាត្រា៩ នៃច្បាប់នេះ គណបក្សនយោបាយនោះត្រូវស្នើសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ដើម្បីទទួលបានសុពលភាព និងអាចធ្វើសកម្មភាពបានដោយស្របច្បាប់ក្នុងឋានៈជានីតិបុគ្គល ដោយត្រូវមានសមាជិកយ៉ាងតិច ៤០០០ (បួនពាន់)នាក់ និងត្រូវបំពេញបែបបទ និងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ។*

*គណបក្សនយោបាយដែលមិនទទួលបានការចុះបញ្ជី ស្របតាមបទប្បញ្ញត្តិនៃជំពូកនេះ មិនអាចធ្វើសកម្មភាពនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ។"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា២៥.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា២៥.-ថ្មី ដោយកែប្រែពាក្យពី *"ក្រុមប្រឹក្សាធម្មនុញ្ញ"* ទៅជា *"តុលាការកំពូល"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា២៦.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា២៦.-ថ្មី ដោយមានបន្ថែមថ្មី២វាក្យខណ្ឌ គឺ វាក្យខណ្ឌទី១ និងទី២ ដែលចែងពីៈ

*"គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ ត្រូវបញ្ជូនទៅក្រសួងមហាផ្ទៃនូវបញ្ជីឈ្មោះប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ ក្នុងករណីដែលមានអនុប្រធាន និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេប ដែលមានបិទរូបថតទំហំ ០៤(បួន) គុណនឹង ០៦(ប្រាំមួយ) ។*

*ការផ្លាស់ប្តូរប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេបរបស់សមាសភាពថ្មី ដែលមានបិទរូបថតទំហំ ០៤ (បួន) គុណនឹង០៦(ប្រាំមួយ)។*

*គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ អាចប្តូរឈ្មោះ សញ្ញាសម្គាល់ ទីស្នាក់ការកណ្តាល កែប្រែគោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗ ឬធ្វើវិសោធនកម្មលើលក្ខន្តិកៈ*

*បាន ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយខ្លួន។ ក្នុងករណីនេះគណបក្សនយោបាយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវសំណុំឯកសារថ្មីដែលកែប្រែរួចហើយ។"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា២៩.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា២៩.-ថ្មី ដោយកែប្រែពាក្យ "*អង្គការក្រៅរដ្ឋា - ភិបាល*" ទៅជា "*អង្គការមិនមែនរដ្ឋាភិបាល*" ដើម្បីឱ្យស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងបន្ថែមមួយវាក្យខណ្ឌ ដែលចែងពី "*គណបក្សនយោបាយត្រូវបានហាមឃាត់មិនឱ្យទទួលវិភាគទាន ទោះតាមរូបភាពណាក៏ដោយពីស្ថាប័នបរទេស ក្រុមហ៊ុនបរទេស ជនបរទេស ឬអង្គការដែលមានប្រភពហិរញ្ញប្បទានពីបរទេស។"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា៣៤.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៣៤.-ថ្មី ដែលចែងពី "*គ្មានសមត្ថកិច្ចណាមានសិទ្ធិរំលាយគណបក្សនយោបាយណាមួយបានឡើយ លើកលែងគណបក្សនោះ ត្រូវបានរំលាយដោយតុលាការ។"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា៣៨.-ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៣៨.-ថ្មី ជាមាត្រាតាក់តែងថ្មី ដែលចែងពី "*គ្រប់គណបក្សនយោបាយទាំងអស់ត្រូវគោរពរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា។*

*ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តខុសទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃអាចចាត់វិធានការដូចខាងក្រោម÷*

*- ចេញលិខិតជូនដំណឹងឱ្យគណបក្សនយោបាយនោះ ធ្វើការកែតម្រូវក្នុងរយៈពេលមួយជាកំណត់។*

*- ធ្វើការព្រមានជាលាយលក្ខណ៍អក្សរ និងចាត់វិធានការបញ្ឈប់សកម្មភាពខុសច្បាប់ក្នុងករណីចាំបាច់។*

*- សម្រេចផ្អាកសកម្មភាពរបស់គណបក្សនយោបាយនោះជាបណ្តោះអាសន្នក្នុងរយៈពេលមួយជាកំណត់។*

*- ប្តឹងទៅតុលាការកំពូល ដើម្បីរំលាយគណបក្សនយោបាយនោះ ក្នុងករណីកំហុសមានលក្ខណៈធ្ងន់ធ្ងរ។*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៥២ និង មាត្រា ១៣០ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា៣៩.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៣៩.-ថ្មី ដោយកែប្រែខ្លឹមសារមាត្រា៣៨ ចាស់ ដែលចែងពី *"ត្រូវផាកពិន័យជាប្រាក់ចំនួន ៥ ០០០ ០០០ (ប្រាំលាន)រៀលដោយក្រសួងមហាផ្ទៃ ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៣១នៃច្បាប់នេះ។*

  *ក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសទៀត ផាកពិន័យជាប្រាក់ទ្វេមួយជាពីរ ហើយក្រសួងមហាផ្ទៃអាចសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្ដោះអាសន្ន ក្នុងរយៈពេលមួយជាកំណត់។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤០.-ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤០.-ថ្មី ដោយកែប្រែខ្លឹមសារមាត្រា៣៩ ចាស់ ដែលចែងពី *"គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា២៩ថ្មី នៃច្បាប់នេះ ត្រូវផាកពិន័យជាប្រាក់ដោយក្រសួងមហាផ្ទៃចំនួន ២០ ០០០ ០០០ (ម្ភៃលាន)រៀល។ ក្នុងករណីវិភាគទានដែលគណបក្សនយោបាយបានទទួលដោយល្មើសនឹងមាត្រា២៩ថ្មី នៃច្បាប់នេះ មានតម្លៃលើសពី ២០ ០០០ ០០០ (ម្ភៃលាន)រៀល ត្រូវផាកពិន័យជាប្រាក់ទ្វេមួយជាពីរនៃតម្លៃនៃវិភាគទាននោះ។ ក្រសួងមហាផ្ទៃ អាចសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្ដោះអាសន្នក្នុងរយៈពេលមួយជាកំណត់។*

  *ក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសទៀត ត្រូវផាកពិន័យជាប្រាក់ទ្វេមួយជាពីរនៃប្រាក់ពិន័យលើកមុន ហើយក្រសួងមហាផ្ទៃអាចប្ដឹងរំលាយគណបក្សនយោបាយនោះទៅតុលាការកំពូល។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤១.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤១.-ថ្មី ដោយកែប្រែខ្លឹមសារមាត្រា៤០ ចាស់ ដែលចែងពី *"ត្រូវផាកពិន័យជាប្រាក់ចំនួន ៣ ០០០ ០០០ (បីលាន)រៀល ដោយក្រសួងមហាផ្ទៃ ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៥ និងកថាខណ្ឌទី២ មាត្រា១៥ នៃច្បាប់នេះ។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤២.-ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤២.-ថ្មី ដោយកែប្រែខ្លឹមសារមាត្រា៤១ ចាស់ ដែលចែងពី *"ត្រូវផាកពិន័យជាប្រាក់ចំនួន ១០ ០០០ ០០០ (ដប់លាន)រៀល ដល់ ២០ ០០០ ០០០ (ម្ភៃលាន) រៀល និង/ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ)ខែ ដល់ ០១ (មួយ)ឆ្នាំ ចំពោះជនណាដែលបានប្រព្រឹត្ត..."* និងបានកែសម្រួលរយៈពេលពី ១៨ ខែ មក ១៨០ ថ្ងៃវិញនៅចំណុចទី៣ ព្រមទាំងបន្ថែមមួយចំណុចទៀត គឺចំណុចទី៤ ដែលចែងពី *"នៅតែបន្តធ្វើសកម្មភាពក្នុងនាមគណបក្សនយោបាយខ្លួន ទោះជាមានសេចក្ដីសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះក៏ដោយ។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤៣.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤៣.-ថ្មី ជាមាត្រាតាក់តែងថ្មី ដែលចែងពី *"បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ ដូចមានចែងក្នុងជំពូកនេះ អាចប្តឹងតវ៉ាទៅតុលាការកំពូលក្នុងអំឡុងពេល ៣០ (សាមសិប)ថ្ងៃ គិតពីកាលបរិច្ឆេទទទួលបានសេចក្តីសម្រេចនេះ។ ក្នុងអំឡុងពេលនៃការប្តឹងតវ៉ា និងអំឡុងពេលនៃការដោះស្រាយបណ្តឹងតវ៉ា សេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ មិនមានអានុភាពអនុវត្តឡើយ លើកលែងតែសេចក្តីសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយជាបណ្តោះអាសន្ន។"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី និង មាត្រា ១២៩ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤៤.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤៤.-ថ្មី ជាមាត្រាតាក់តែងថ្មី ដែលចែងពី *"ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៦ថ្មី និងមាត្រា៧ នៃច្បាប់នេះ តុលាការអាចសម្រេចដូចខាងក្រោម÷*

  *-ផ្អាកសកម្មភាពគណបក្សនយោបាយនោះក្នុងរយៈពេលមិនលើសពី ៥ ឆ្នាំ។*

  *-រំលាយគណបក្សនយោបាយនោះ។"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤៥.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤៥.-ថ្មី ជាមាត្រាតាក់តែងថ្មីដែលចែងពី *"តុលាការដែលមានសមត្ថកិច្ច ដើម្បីពិនិត្យលើបណ្តឹងនានាដោយអនុវត្តតាមច្បាប់នេះ គឺតុលាការកំពូល។ ដោយឡែកចំពោះមាត្រា៤២ថ្មី នៃច្បាប់នេះ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។*

  *តំណាងមហាអយ្យការអមតុលាការកំពូលត្រូវចូលរួមសុំឱ្យមានការគោរពច្បាប់ នៅក្នុងពេលដែលមានបណ្តឹងដាក់ជូនតុលាការកំពូលពិនិត្យ។*

  *ក្នុងករណីដែលគណបក្សនយោបាយត្រូវបានរំលាយ តុលាការអាចសម្រេចហាមឃាត់ការធ្វើសកម្មភាពនយោបាយរបស់ថ្នាក់ដឹកនាំនៃគណបក្សនយោបាយនោះ សម្រាប់រយៈពេល ០៥ (ប្រាំ)ឆ្នាំបាន។*

  *តុលាការកំពូលត្រូវសម្រេចសេចក្តីលើអង្គហេតុ និងអង្គច្បាប់ ដោយសភាពេញអង្គ។ សាលដីការបស់តុលាការកំពូលជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤៦.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤៦.-ថ្មី ជាមាត្រាតាក់តែងថ្មីដែលចែងពី *"ការអនុវត្តជំពូកនេះ មិនរារាំងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ ក្នុងករណីដែលអំពើបំពានលើបញ្ញត្តិដែលចែងក្នុងជំពូកនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌ។"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤៧.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤៧.-ថ្មី ជាមាត្រាតាក់តែងថ្មីដែលចែងពី *"បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខិតបង្ខំរូបកាយ) នៃមាតិកាទី៣ (ការបង្ខិតបង្ខំរូបកាយ) នៃគន្ថីទី៨ (នីតិវិធីប្រតិបត្តិ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្ដីសម្រេចអំពីប្រាក់ពិន័យបានចូលជាស្ថាពរ។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤៨.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤៨.-ថ្មី ជាមាត្រា៤៣ចាស់ដែលចែងពី *"បន្ទាប់ពីច្បាប់នេះចូលជាធរមាន គណបក្សនយោបាយទាំងអស់ដែលត្រូវបានបង្កើត និងបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ត្រូវបន្តសុពលភាព និងអាចធ្វើសកម្មភាពស្របតាមច្បាប់នេះ និងច្បាប់ជាធរមានផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែគណបក្សនយោបាយទាំងនេះ ត្រូវបំពេញសំណុំបែបបទធ្វើនិយ័តកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃ យ៉ាងយូរ គិតពីថ្ងៃដែលច្បាប់នេះចូលជាធរមាន។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤៩.-ថ្មី ជាមាត្រា៤៤ ចាស់ដែលចែងពី *"បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវចាត់ទុកជានិរាករណ៍។"*

  មាត្រានេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- មាត្រា៥០.-ថ្មី ជាមាត្រា៤៥ ចាស់ ដែលចែងពី *"ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់។"*

  មាត្រានេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា **មាត្រាមួយ** នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **មាត្រាពីរ** ដែលចែងថាច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

អ៊ឹម ឈុនលឹម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សាធម្មនុញ្ញ
ទទួល លេខ ១៤/២០១៧
ថ្ងៃ ១/៣/១៧ ម៉ោង ១០:០០

រដ្ឋសភា

លេខ: ០៧៥ រស.

**សូមជម្រាបជូន**

**ឯកឧត្តម អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

សូមជ្រាប ។

**កម្មវត្ថុ: ការពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មច្បាប់ស្ដីពី គណបក្សនយោបាយ ។**

**យោង:** -មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ

-មាត្រា ១៦ ថ្មី ផ្នែកទី ២ ជំពូកទី ២ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-លិខិត ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៧ របស់ឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** និង ឯកឧត្តម **ឈាង វុន** តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីចំនួន ៦០ រូប

-លិខិតលេខ ០១៧/០២១៧/ពស/នវ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ របស់ព្រឹទ្ធសភា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានទទួលសេចក្ដីស្នើរបស់ឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** និងឯកឧត្តម **ឈាង វុន**តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីចំនួន ៦០ រូប សុំឲ្យរដ្ឋសភាពិនិត្យ និងអនុម័ត**សេចក្ដីស្នើច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពី គណបក្សនយោបាយ** ។

រដ្ឋសភាអនុម័តយល់ព្រមលើសេចក្ដីស្នើ វិសោធនកម្ម ខាងលើដោយទទួលបានចំនួន ៦៦ សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូលនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧ នាសម័យប្រជុំរដ្ឋសភា ជាវិសាមញ្ញ នីតិកាលទី ៥ ហើយព្រឹទ្ធសភាក៏បានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី ៣ នាថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ ។

អាស្រ័យដោយហេតុថា ច្បាប់នេះជាច្បាប់រៀបចំអង្គការ ខ្ញុំសូមជូនឯកឧត្តមប្រធានចាត់ **ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ដែលមានជូនភ្ជាប់មកជាមួយជាការប្រញាប់** តាមការគួរ ។

ខ្ញុំសូម **ឯកឧត្តម** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៧

**ប្រធានរដ្ឋសភា**

**សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន**

**ចម្លងជូន:**

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

ដើម្បីជ្រាបជាព័ត៌មាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៦០/០០១/២០១៧ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧

**ជម្រាបមក**

**លោក គល់ បញ្ញា នាយកប្រតិបត្តិអង្គការខុមហ្វ្រែល** COMFREL

**កម្មវត្ថុ** ៖ អំពីសំណើសុំការពិនិត្យធម្មនុញ្ញភាពនៃសេចក្តីស្នើច្បាប់ស្តីពីច្បាប់ស្តីពីគណបក្សនយោបាយ។

**យោង** ៖ លិខិតរបស់លោក លេខ ០២៨/១៧ គ.ប.ស.យ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកថា ក្រុមប្រឹក្សាធម្មនុញ្ញពុំអាចលើកយកសំណើរបស់លោកមកពិនិត្យបានឡើយ ដោយលោកពុំមានគុណវុឌ្ឍិស្របតាមទម្រង់ដែលមានចែងក្នុងមាត្រា ១៤០ថ្មី មាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៧ថ្មី មាត្រា ១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០១០៧/ ០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧។

សូមលោកនាយកប្រតិបត្តិអង្គការខុមហ្វ្រែល ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**អ៊ឹម ឈុនលឹម**

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
Committee For Free And Fair Elections In Cambodia (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Toul Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 / 12 942 019, Fax: (855) 23 883 750, E-mail: comfrel@online.com.kh, comfrel@comfrel.org, Site: http://www.comfrel.org

ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

1. លោក ធុន សារាយ
Mr. THUN Saray
ប្រធានគណៈកម្មាធិការនាយក និងជាប្រធាន ADHOC

2. លោក សុក សំអឿន
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក និងជានាយកប្រតិបត្តិ CDP

3. លោក យង់ គិមអេង
Mr. YONG Kim Eng
អគ្គនាយក-នាយកប្រតិបត្តិ PDP-Center

4. លោក យឹម ប៉ូ
Mr. YIM Po នាយករង CPDEW

5. លោកស្រី ស៊ុន ចាន់សែន
Ms. SUN Chansen
ឥស្សរជន-Dignitary

6. លោក ម៉ាក់ ចំរើន
Mr. MAK Chamroeun
ប្រធាន KYA

7. លោកស្រី ប៉ុក បញ្ញាវិចិត្រ
Ms. POK Panhavichetr
នាយិកាប្រតិបត្តិ CWCC

8. លោក មុំ សារិន
Mr. MOM Sarin
នាយកប្រតិបត្តិ HRCDO

9. លោក គីម សុវណ្ណ
Mr. KIM Sovann
នាយកប្រតិបត្តិ VIGILANCE

10. លោក សេន សែត
Mr. SEN Set, Dignitary

11. លោក ជាង សុខា
Mr. CHEANG Sokha
នាយកប្រតិបត្តិ YRDP

លេខ...០២៤/.១៧...គ.ប.ស.យ

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល លេខ ៣៧/ ២០១៧
ថ្ងៃ២៣/២/១៧ម៉ោង៩:០០
បញ្ជូន

**គោរពជូន**

**ឯកឧត្តម អ៊ឹម ឈុនលឹម**

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** ស្នើសុំការពិនិត្យធម្មនុញ្ញភាពនៃសេចក្តីស្នើច្បាប់ស្តីពីច្បាប់ស្តីពីគណបក្សនយោបាយ

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយស សូមជម្រាបឯកឧត្តមប្រធានមេត្តាជ្រាបថា សេចក្តីស្នើច្បាប់ស្តីពីច្បាប់ស្តីពីគណបក្សនយោបាយត្រូវបានរដ្ឋសភានីតិកាលទី៥ អនុម័តក្នុងកិច្ចប្រជុំពេញអង្គវិសាមញ្ញកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយសម្លេងគាំទ្រ៦៦សម្លេងនៃតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ដោយតំណាងរាស្ត្រនៃគណបក្សសង្គ្រោះបានធ្វើពហិការមិនចូលរួមកិច្ចប្រជុំពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់នេះ។

ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជាបានសិក្សា និងបានឈ្វេងយល់ឃើញថា សេចក្តីស្នើច្បាប់នេះ មិនស្របតាមគោលការណ៍រដ្ឋធម្មនុញ្ញប្រជាធិបតេយ្យសេរីពហុបក្ស សិទ្ធិចូលរួមសកម្មក្នុងជីវភាពនយោបាយ សេរីភាពបង្កើតគណបក្សនយោបាយ និងសេរីភាពបញ្ចេញមតិ ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញមាត្រា៣៥។ មាត្រា០១នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបានចែងថាកម្ពុជាប្រកាន់យករបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស។ ដំណើរការពង្រាង និងអនុម័តសេចក្តីស្នើច្បាប់ត្រូវបានការចូលពីគ្រប់ភាគីពាក់ព័ន្ធ និងគណបក្សនយោបាយដែលមានអសនៈក្នុងរដ្ឋសភា។ ការដែលសេចក្តីស្នើច្បាប់នេះត្រូវបានអនុម័តដោយតំណាងរាស្ត្រនៃគណបក្សនយោបាយតែមួយគត់នោះ នឹងនាំមកនូវភាពមិនស្មើគ្នាក្នុងការប្រកួតប្រជែងក្នុងការបោះឆ្នោត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាពិនិត្យលើធម្មនុញ្ញភាពនៃសេចក្តីស្នើ ច្បាប់នេះឲ្យស្របតាមគោលការណ៍ប្រជាធិបតេយ្យ សេរីពហុបក្ស នៃស្មារតីរដ្ឋធម្មនុញ្ញ មុននឹងដាក់ថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខា និងចូលជាធរមាន។

សូមឯកឧត្តម មេត្តាទទួលនូវសេចក្តីគោរពរាប់អានអំពីយើងខ្ញុំ។

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧

**នាយកប្រតិបត្តិ**

COMFREL

**គល់ បញ្ញា**

<u>ភ្ជាប់ជូនជាមួយ៖</u>
សេចក្តីថ្លែងការរួមស្តីពី៖ ត្រូវគោរព និងការពារសិទ្ធិសេរីភាពអ្នកនយោបាយ គណបក្សនយោបាយ និងឆន្ទៈប្រជាពលរដ្ឋ ដើម្បីធានារបបប្រជាធិបតេយ្យ សេរីពហុបក្ស និងការបោះឆ្នោតសេរី និងយុត្តិធម៌

<u>ចម្លងជូន៖</u> សមាជិកក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ (០៨រូប)

**សេចក្តីថ្លែងការណ៍រួម**

**ស្តីពី**

**ត្រូវគោរព និងការពារសិទ្ធិសេរីភាពអ្នកនយោបាយ គណបក្សនយោបាយ**

**និងឆន្ទៈប្រជាពលរដ្ឋ ដើម្បីធានារបបប្រជាធិបតេយ្យ សេរីពហុបក្ស និងការបោះឆ្នោតសេរី**

**និងយុត្តិធម៌**

**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៧**

សេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ធ្វើឡើងតាមសំណើរបស់នាយករដ្ឋមន្ត្រី និងតំណាងរាស្ត្រគណបក្សកាន់អំណាច មានចេតនាដើម្បីផ្អាក បញ្ឈប់ ឬរំលាយគណបក្សនយោបាយ និងប្រធាន និងថ្នាក់ដឹកនាំគណបក្សនយោបាយ។ ការអនុវត្តន៍នៃចេតនានេះ គឺជាឧបករណ៍នយោបាយដែលនឹងរារាំង ឬបំបិទការចូលរួមសកម្ម និងការប្រកួតប្រជែងរបស់គណបក្សនយោបាយក្នុងការបោះឆ្នោតឆ្នាំ២០១៧ និង២០១៨ខាងមុខនេះ។

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត(ERA) និងអង្គការសង្គមស៊ីវិលនៅកម្ពុជា មិនអាចទទួលយកការរៀបចំ និងខ្លឹមសារមាត្រាមួយចំនួននៃសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលមិនស្របតាមគោលការណ៍រដ្ឋធម្មនុញ្ញប្រជាធិបតេយ្យសេរីពហុបក្ស សិទ្ធិចូលរួមសកម្មក្នុងជីវភាពនយោបាយ សេរីភាពបង្កើតគណបក្សនយោបាយ និងសេរីភាពបញ្ចេញមតិ។ ខ្លឹមសារនៃសេចក្តីស្នើច្បាប់នេះ គឺបានផ្តល់អំណាចឲ្យក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលនៃគណបក្សកាន់អំណាច និងតុលាការក្នុងការបកស្រាយសកម្មភាពហាមឃាត់ កំហុស ឬបទល្មើស របស់គណបក្សនយោបាយណាមួយដែល៖ «ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ» ឬ/និង ការ «ធ្វើការញុះញង់ដែលអាចនាំឲ្យមានការបែកបាក់ជាតិ» ដែលបានចែងក្នុងមាត្រា៦ថ្មីនៃសេចក្តីស្នើវិសោធនកម្មច្បាប់នេះ។ កន្លងមកព្រោះតែការបញ្ចេញមតិ និងសកម្មភាពនយោបាយ តែក្រោមហេតុផលសន្តិសុខ ឬ/និងបទល្មើសញុះញង់ រាជរដ្ឋាភិបាល និងអាជ្ញាធរ បានអន្តរាគមន៍បង្ក្រាប និងប្តឹងរហូតដល់ឲ្យមានការចោទប្រកាន់ពីតុលាការលើអ្នកនយោបាយ អ្នកតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា នៃគណបក្សប្រឆាំងជាច្រើនរូប ព្រមទាំង សកម្មជនការពារសិទ្ធិមនុស្ស និងអ្នកវិភាគពីបញ្ហានយោបាយ និងសង្គមផ្សេងទៀត។

សេចក្តីស្នើច្បាប់នេះ ហាមមិនឲ្យបុគ្គលជាទណ្ឌិតជាប់ទោសដាក់ពន្ធនាគារ ពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ក្លាយជាប្រធាន/អនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ (មាត្រា១៨ថ្មី)។ បទបញ្ញត្តិនេះបានរំលោភសេរីភាពបុគ្គលចូលរួមក្នុងគណបក្សនយោបាយ និងសិទ្ធិបុគ្គលចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ ដែលបានធានាក្នុងរដ្ឋធម្មនុញ្ញ។ ការហាមឃាត់ដែលមានចែងក្នុងបទបញ្ញត្តិនេះបង្ហាញ ការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលនៃគណបក្សកាន់អំណាចក្នុងកិច្ចការផ្ទៃក្នុងរបស់គណបក្សនយោបាយផ្សេងៗ និងរឹតត្បិតសកម្មភាពនយោបាយរបស់គណបក្ស។

សេចក្តីស្នើច្បាប់នេះក៏បាន ផ្តល់អំណាចឲ្យក្រសួងមហាផ្ទៃ ក្នុងការបញ្ឈប់ ឬការផ្អាកសកម្មភាពនយោបាយ និងរហូតដល់ប្តឹងទៅតុលាការកំពូលដើម្បីរំលាយគណបក្សនយោបាយណាមួយ ក្នុងករណីបើមាន «កំហុសធ្ងន់ធ្ងរ» ដែលអាចបកស្រាយយ៉ាងទូលំទូលាយជុំវិញបញ្ហា «ប៉ះពាល់សន្តិសុខនៃរដ្ឋ ឬការញុះញង់ឲ្យមានការបែកបាក់ជាតិ»

ក្នុងមាត្រា៦ថ្មី មាត្រា៣៨ថ្មី និងមាត្រា៤៤ថ្មី។ ការឲ្យអំណាចទៅក្រសួងមហាផ្ទៃនៃនីតិប្រតិបត្តិ នៃគណបក្សកាន់អំណាច នឹងបង្កើតទំនាស់ផលប្រយោជន៍នៃការប្រើអំណាចទៅបញ្ឈប់ ឬផ្អាកសកម្មភាពគណបក្សដែលប្រកួតប្រជែងជាមួយខ្លួន។ម្យ៉ាងទៀត ចៅក្រម និងមន្ត្រីតុលាការកម្ពុជានៅមិនទាន់មានឯករាជ្យភាពពេញលេញ និងមួយចំនួនជាសមាជិកនៃគណបក្ស ដែលជាហេតុអាចធ្វើឲ្យការអនុវត្តច្បាប់បែបនេះមិនត្រឹមត្រូវ និងក្រោមសម្ពាធនយោបាយ។

ការអនុម័តសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយនេះ ក៏នឹងឈានដល់ការលុបបំបាត់ឆន្ទៈនយោបាយរបស់ប្រជាពលរដ្ឋដែលផ្តល់ឲ្យ តំណាងជាប់ឆ្នោតរបស់ខ្លួនតាមរយៈការបោះឆ្នោត។ ក្នុងករណីរំលាយគណបក្សនោះនឹងបាត់បង់អស់នូវអសនៈជាអ្នកតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា និង/ឬសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ និងរាជធានី/ខេត្តដែលខ្លួនមាន នេះបើយោងតាមច្បាប់បោះឆ្នោត និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ និងរាជធានី/ខេត្ត។

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) និងអង្គការសង្គមស៊ីវិលនៅកម្ពុជា មើលឃើញថាច្បាប់ស្តីពីគណបក្សនយោបាយត្រូវគោរពសិទ្ធិសេរីភាពខាងនយោបាយ និងការប្រកួតប្រជែងនៃគណបក្សនយោបាយស្របតាមការបោះឆ្នោតសេរី យុត្តិធម៌ និងប្រជាធិបតេយ្យសេរីពហុបក្សដែលប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស អង្គការសហប្រជាជាតិត្រូវបន្តធានា និងគោរព។

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) និងអង្គការសង្គមស៊ីវិលនៅកម្ពុជា សូមស្នើថា មិនត្រូវអនុម័តវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយនេះដោយឯកបក្សនៃគណបក្សកាន់អំណាច នាពេលដែលការបោះឆ្នោតកាន់តែខិតជិតចូលមកដល់នោះទេ។

**សម្រាប់ព័ត៌មានបន្ថែម៖**

| ឈ្មោះ | អង្គការ | លេខទូរស័ព្ទ |
|---|---|---|
| • លោកស្រី រស់ សុភាព | GADC | ០១២ ៦២៧ ៨៥៧ |
| • លោក គល់ បញ្ញា | COMFREL | ០១២ ៩៤២ ០១៧ |
| • លោកស្រី ចក់ សុភាព | CCHR | ០១១ ៩៤ ៣២ ១៣ |
| • លោក ប៉ា ងួនទៀង | CCIM | ០៦០ ៤០ ៩៩ ៩៩ |
| • លោក យង់ គិមអេង | PDP-Center | ០១៦៨២៨ ២១១ |
| • លោក សៀ ភារម្យ | HRTF | ០១២ ៨៥ ២៣ ២៥ |
| • លោកស្រី ស៊ុំ កល្យាណ | KYDS | ០១២ ៥៦ ៥៣ ៥២ |
| • លោក ជាង សុខា | YRDP | ០១២ ៣៦០ ៤៦៤ |
| • លោក សំ គន្ធាមី | NICFEC | ០១២ ៨២២ ២៧៣ |
| • លោក សួន ប៊ុនស័ក្ត | CISA | ០៩២ ៣៤៤ ៣៥៧ |
| • លោក សន ជ័យ | ANSA Cambodia | ០១២៨៤៥៦៤២ |
| • លោក មឿន តុលា | CENTRAL | ០៩៣ ៥៥៦ ៦៤៣ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៤៩ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៦ ៥០៤ ០០០ ០០០ រៀល (ប្រាំមួយបីលានប្រាំរយបួនលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងព្រះបរមរាជវាំង សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយរៀបចំជួសជុលសួនច្បារ និងខ្លោងទ្វារ-របងព័ទ្ធជុំវិញទីវាលព្រះមេរុ។

**មាត្រា៣._**

រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៧៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១ .-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឯកជនមួយ ដែលមានឈ្មោះថា "វិទ្យាស្ថាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី" ដែលមានអក្សរកាត់ "វ.វ.ប.អ." និងជាភាសាអង់គ្លេស "Australian Institute of Science and Technology" ដែលមានអក្សរកាត់ "AIST"។

**មាត្រា២ .-**

វិទ្យាស្ថាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី មានទីតាំងស្ថិតនៅភូមិប៉ាយាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ វិទ្យាស្ថាននេះស្ថិតនៅក្រោមឱវាទក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៣ .-**

វិទ្យាស្ថាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី មានភារកិច្ចធ្វើការបណ្តុះបណ្តាលៈ

- កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ដែលមានយ៉ាងតិច៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស ឬសញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ដែលមានយ៉ាងតិច១២០ក្រេឌីត
- កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ដែលមានយ៉ាងតិច៤៥ក្រេឌីត។

**មាត្រា៤ .-**

វិទ្យាស្ថាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី ធ្វើការបណ្តុះបណ្តាលលើមុខជំនាញដូចខាងក្រោមៈ

- គ្រប់គ្រង
- បដិសណ្ឋារកិច្ចនិងគ្រប់គ្រងទេសចរណ៍
- រដ្ឋបាលសាធារណៈ
- វិទ្យាសាស្ត្រកុំព្យូទ័រ
- ស្ថាបត្យកម្ម
- គ្រប់គ្រងនិងសហគ្រិនភាព
- គណនេយ្យ
- គណនេយ្យនិងសវនកម្ម
- ធនាគារ ហិរញ្ញវត្ថុ និងមីក្រូហិរញ្ញវត្ថុ
- ហិរញ្ញវត្ថុនិងធានារ៉ាប់រង
- ម៉ាឃីតធីងនិងការគ្រប់គ្រង
- អប់រំ
- គណនេយ្យនិងហិរញ្ញវត្ថុ
- ពន្ធដារនិងសវនកម្ម
- អក្សរសាស្ត្រអង់គ្លេស
- ព័ត៌មានវិទ្យា
- វិស្វកម្មសំណង់ស៊ីវិល
- ទីផ្សារនិងស្រាវជ្រាវ
- គណនេយ្យនិងពន្ធដារ
- គណនេយ្យ សវនកម្ម និងពន្ធដារ
- ហិរញ្ញវត្ថុនិងទីផ្សារមូលបត្រ
- ហិរញ្ញវត្ថុ ទីផ្សារមូលបត្រ និងធានារ៉ាប់រង
- ច្បាប់
- សុវត្ថិភាពព័ត៌មាននិងការបង្កើតកម្មវិធី/ង៉ែ

- វិស្វកម្មមេកានិច
- សរសេរកម្មវិធីនិងរចនាគេហទំព័រ
- ស្ថាបត្យកម្មតុបតែងនិងការរចនាផ្ទៃខាងក្នុង
- ការគ្រប់គ្រងការសាងសង់
- អេឡិចត្រូនិច
- ការគ្រប់គ្រងសេវាកម្មចំណីអាហារ
- រចនាផលិតផលនិងគ្រឿងសង្ហារិម
- ការថតរូប ភាពយន្ត និងផលិតព័ត៌មាន
- ការរចនានិងផលិតព័ត៌មាន
- ការស្វែងរកទីផ្សារនិងការផ្សព្វផ្សាយពាណិជ្ជកម្ម
- ព័ត៌មាននិងបច្ចេកទេសវេបសាយ
- ការគ្រប់គ្រងអាជីវកម្មខ្នាតតូច
- អចលនទ្រព្យនិងការវាយតម្លៃ
- អគ្គិសនី
- អាជីវកម្មនិងពាណិជ្ជកម្មអន្តរជាតិ
- ការដាំដុះនិងចិញ្ចឹម(ផ្នែកកសិកម្ម)
- ការរចនាសេរ៉ាមិច
- គណនេយ្យនិងហិរញ្ញវត្ថុ
- ការគ្រប់គ្រងភស្តុភា
- ការរចនាម៉ូត។

នៅថ្ងៃអនាគត វិទ្យាស្ថាននេះអាចបើកសាខា ប្តូរទីតាំង ដេប៉ាតឺម៉ង់ថ្មី ឯកទេសថ្មី មហាវិទ្យាល័យ ដំឡើងកម្រិតឬថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ឬបន្ថែមជំនាញផ្សេងៗទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៥ .-**

វិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦ .-**

នាយកវិទ្យាស្ថាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី និងធានាឲ្យមានសុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសសិស្ស និស្សិតឲ្យចូលរៀន ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គោរពនិងអនុវត្តតាមការណែនាំនិងបទដ្ឋានរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានកំណត់អំពីសកម្មភាពនៃការធានាគុណភាពក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ជូននាយកដ្ឋានពាក់ព័ន្ធនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យបានទៀងទាត់តាមការកំណត់។/.

**មាត្រា៧ .–**

សិស្ស និស្សិតដែលបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រឬសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រឬសញ្ញាបត្រនេះត្រូវផ្តល់ដោយវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី ដែលមានការទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញនិងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៨ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៩ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នាយកវិទ្យាស្ថាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/.

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីលើកស្ទួយឧស្សាហកម្មកៅស៊ូនាំចេញ

### <u>សម្រេច</u>

**មាត្រា ១.-**

ត្រូវបានកែសម្រួលអត្រាអាករនាំចេញដែលគិតតាមរបៀប “ពន្ធគិតតាមឯកតា” លើមុខទំនិញជ័រកៅស៊ូ ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ដូចខាងក្រោម÷

- ពុំជាប់អាករនាំចេញ បើតម្លៃគិតអាករនាំចេញទាបជាង ១០០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ៥០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ១០០០ ឡើងតែទាបជាង ២០០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ១០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ២០០០ ឡើងតែទាបជាង ៣០០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ២០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៣០០០ ឡើងតែទាបជាង ៤០០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ៣០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៤០០០ ដុល្លារអាមេរិកក្នុង ១ តោន ឡើងទៅ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកចាត់ចែងអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១៧ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៥៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការផ្ដល់មេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

**មាត្រា ១** -. បំពាក់មេដាយសុវត្ថារាថ្នាក់ធិបឌិន្ទ ជូនមន្ត្រីនគរបាលជាតិ និងសប្បុរសជន ដែលមានស្នាដៃល្អក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍមូលដ្ឋានក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | លោក | **តែ សុថារេត** | សប្បុរសជន |
| ២- | លោក | **អ៊ុយ ពិសី** | សប្បុរសជន |
| ៣- | លោកអនុសេនីយ៍ឯក | **ម៉ៅ សុផាន់ណារ៉ា** | អត្តលេខ ៧១៨៧៧ |
| ៤- | លោកអនុសេនីយ៍ឯក | **អ៊ូ សុភាព** | អត្តលេខ ៦៨៨១២ |
| ៥- | លោកអនុសេនីយ៍ឯក | **អាំង តារិទ្ធ** | អត្តលេខ ៦៨៧៧៩ |
| ៦- | លោកអនុសេនីយ៍ត្រី | **យ៉េម តារុណា** | អត្តលេខ ៧០៩២៣ |

**មាត្រា ២**-. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៩០ អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

**មាត្រា ១ -.** បំពាក់មេដាយជូនអស់លោក លោកស្រី មន្ត្រីរាជការ មន្ត្រីនគរបាល និងសប្បុរសជន ដែលមានស្នាដៃល្អក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍមូលដ្ឋានក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមៈ

**ក-មេដាយការងារ ថ្នាក់មាស:**

| | | | |
|---|---|---|---|
| ១- | លោកវរសេនីយ៍ទោ | **ជុំ សោភ័ណ្ឌ** | អត្តលេខ ១៤៥៤៥១ |
| ២- | លោកវរសេនីយ៍ត្រី | **ដេត ភក្ដដា** | អត្តលេខ ៧៣២៥៤ |
| ៣- | លោកអនុសេនីយ៍ឯក | **គ្រី ចាន់ដា** | អត្តលេខ ៧២៣៦៩ |
| ៤- | លោកអនុសេនីយ៍ឯក | **ប្រាក់ ពេញ** | អត្តលេខ ៧២០៥៥ |
| ៥- | លោកអនុសេនីយ៍ទោ | **ជីវ គីមហ៊ុត** | អត្តលេខ ៦៥៤១៨ |
| ៦- | លោកអនុសេនីយ៍ទោ | **ឡាច វិចិត្រ** | អត្តលេខ ៧០៩២២ |
| ៧- | លោកពលបាលត្រី | **គង់ សុផានិត** | អត្តលេខ ៧៦៥៩២ |
| ៨- | លោកស្រី | **រ៉ិត សេដ្ឋា** | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុសាលាស្រុកឯកភ្នំ |
| ៩- | លោក | **ចាប់ សេរីវឌ្ឍនា** | ប្រធានការិយាល័យអន្តរវិស័យសាលាស្រុកឯកភ្នំ |
| ១០- | លោក | **គង់ ម៉ុនរដ្ឋ** | អនុប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុសាលាស្រុកឯកភ្នំ |
| ១១- | លោកស្រី | **ទៀត សារ៉ាឌី** | អនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលស្រុកឯកភ្នំ |
| ១២- | កញ្ញា | **ទៀង នារីហ៊ុន** | មន្ត្រីការិយាល័យផែនការ និងគាំទ្រឃុំសាលាស្រុកឯកភ្នំ |
| ១៣- | លោក | **សែន រស្មី** | សប្បុរសជន |
| ១៤- | លោក | **ពៅ ឌីណា** | សប្បុរសជន |

| | | | |
|---|---|---|---|
| ១៥- | លោក | **ចាន់ សុវណ្ណា** | សប្បុរសជន |
| ១៦- | លោក | **កែវ រដ្ឋវិទ្យា** | សប្បុរសជន |
| ១៧- | លោក | **វ៉ាត គុណារម្មី** | សប្បុរសជន |

**ខ-មេដាយការងារ ថ្នាក់ប្រាក់:**

| | | | |
|---|---|---|---|
| ១- | លោកស្រី | **មេខ ធឿន** | អនុប្រធានការិយាល័យផែនការ និងគាំទ្រឃុំសាលាស្រុកឯកភ្នំ |
| ២- | លោក | **វ៉ាន់ សុឃឿន** | មន្ត្រីការិយាល័យផែនការ និងគាំទ្រឃុំសាលាស្រុកឯកភ្នំ |
| ៣- | លោក | **ឌុច សុផាត** | មន្ត្រីអង្គភាពលទ្ធកម្មរបស់រដ្ឋបាលស្រុកឯកភ្នំ |
| ៤- | លោក | **សម្បត្តិ ពិសិទ្ធិ** | មន្ត្រីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុសាលាស្រុកឯកភ្នំ |
| ៥- | លោក | **ធី វិចិត្ត** | មន្ត្រីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុសាលាស្រុកឯកភ្នំ |
| ៦- | កញ្ញា | **វ៉ាន់ សុឃៀត** | មន្ត្រីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុសាលាស្រុកឯកភ្នំ |
| ៧- | កញ្ញា | **ឡាយ សុឡា** | មន្ត្រីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុសាលាស្រុកឯកភ្នំ |
| ៨- | កញ្ញា | **សួស សុផានី** | មន្ត្រីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុសាលាស្រុកឯកភ្នំ |

**មាត្រា ២-.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...១៩១...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា ១ .-** ដាក់មន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ចំនួន ០២ រូប នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យចូលនិវត្តន៍មុនកាលកំណត់តាមការស្នើសុំ ដូចមានរាយនាមខាងក្រោម ៖

១- លោក **ពេជ្រ រម្យនា** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ ថ្ងៃខែឆ្នាំចូលនិវត្តន៍ ០១-ធ្នូ-២០១៦

២- លោក **ខៀវ សុភ័ក្ស** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ ថ្ងៃខែឆ្នាំចូលនិវត្តន៍ ០១-មីនា-២០១៧

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូច មានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦២ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- យោងតាមសំណើរបស់ឯកឧត្តម **ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស

### សម្រេច

**មាត្រា ១ :** តែងតាំងមន្ត្រីរាជការ ចំនួន ០២រូប ជាជំនួយការឯកឧត្តម **ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដូចខាងក្រោម៖

១-លោក **សេង សំបាន** មានឋានៈស្មើ ប្រធាននាយកដ្ឋាន

២-លោក **ឆាង និត** មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៩៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

**រាជរដ្ឋាភិបាល**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
